# ពិធីបូជាសពនៅកោះ Bali

Jean Filliozat*

*Membre de l'Institut*

ថ្មីៗនេះសាលាបារាំងចុងបូព៌ាបានពង្រីកវិសាលភាពរបស់ខ្លួនឆ្ងាយពីតំបន់ឥណ្ឌូចិន ហើយបានបង្កើតឱ្យមានមណ្ឌលស្រាវជ្រាវជាច្រើននៅក្នុងប្រទេសឥណ្ឌា និងប្រទេសដែលទទួលឥទ្ធិពលឥណ្ឌាផ្សេងទៀតនៅអាស៊ីខាងត្បូង។ ប្រការនេះតម្រូវឱ្យមានការស្រាវជ្រាវអំពីអារ្យធម៌នៃបណ្ដាប្រទេសទាំងនោះឱ្យបានជាប់លាប់ និងនៅក្នុងគោលដៅរួមគ្នា ត្បិតជាតំបន់ដែលមានប្រជាជនរស់នៅច្រើនជាងគេមួយនៃពិភពលោក ហើយអារ្យធម៌នៃបណ្ដាប្រទេសទាំងនេះក៏មានទំនាក់ទំនងគ្នាទៅវិញទៅមកដែរ។ ម្យ៉ាងទៀតតំបន់នេះមានឯកសារបុរាណវិទ្យា, សិលាចារិក និងឯកសារខាងភាសាសាស្ត្របុរាណជាច្រើន ដែលមានរាប់សតវត្សមកហើយ។

ការសិក្សាដែលធ្វើស្របគ្នានៅក្នុងប្រទេសឥណ្ឌាផង និងនៅអាស៊ីភាគអាគ្នេយ៍ផង បានជម្រុញឱ្យមានការស្រាវជ្រាវជាពិសេស អំពីពិធីផ្សេងៗនៅស្រុកឥណ្ឌានិងនៅកោះ Bali។ ឧទាហរណ៍ដូចមានតទៅនេះ កើតឡើងយូរមកហើយ ជាការដែលពុំបានរៀបចំគ្រោងទុកមុនមែនពិត ប៉ុន្តែមានសារៈសំខាន់។ លោក Sylvain Lévi ជាគ្រូរបស់ខ្ញុំ បានទទួលសំណេរជាភាសាសំស្ក្រឹត កត់ត្រាជាអក្សរ Bali នៅពេលដែលគាត់ស្នាក់នៅកោះ Bali ក្នុងរយៈពេលខ្លីមួយ ពីខែកក្កដាដល់ខែសីហាឆ្នាំ១៩២៨។ អត្ថបទនេះត្រូវបានពួកអាចារ្យយកមកប្រើប្រាស់ដោយអន្លើនៅឡើយ។ លោកគ្រូ Sylvain Lévi បានផ្សព្វផ្សាយអត្ថបទទាំងនោះក្នុងទស្សនាវដ្ដី *Gaekwad's Oriental Series* ក្រោមចំណងជើងថា *Sanskrit texts from Bali* នៅក្រុង Baroda កាលពីឆ្នាំ១៩៣៣។ ទេសកាលដែលធ្វើឱ្យគាត់បានពើបប្រទះផ្ទាល់នឹងឯកសារទាំងនោះ គាត់ពុំបានរ៉ាយរ៉ាប់ក្នុងអត្ថបទរបស់គាត់ឡើយ ប៉ុន្តែគាត់បាននិយាយប្រាប់ខ្ញុំ ហើយខ្ញុំយល់ថាមានប្រយោជន៍នឹងយកមកលាតត្រដាងនៅទីនេះ។

Bali ជាកោះឥណ្ឌូណេស៊ីតូចមួយ ស្ថិតនៅចំខាងកើតកោះ Java ដាច់ពីគ្នាដោយដៃសមុទ្រតូចមួយ។ ម្យ៉ាងទៀត គេដឹងយូរមកហើយថា អត្ថបទគម្ពីរវេទអាចមាននៅលើកោះនេះ។ ការគោរពបូជាដល់ព្រះឥសូរ និងពុទ្ធសាសនាមាននៅដល់សព្វថ្ងៃ។ ប្រទេសហូឡង់ដ៏មានផ្សព្វផ្សាយសំណេរសំខាន់ៗជាច្រើន នៅក្នុងនោះក៏មានលើករឿងនេះមកនិយាយផងដែរ ដូចជាសៀវភៅរបស់បណ្ឌិត R. Goris ឈ្មោះ *Bijtrage tot de Kennis der Oud-Javaansche en Balineesche Theologie* (Leiden, 1926)។

ពេលលោក Sylvain Lévi ស្នាក់នៅលើកោះ Bali គាត់ជាភ្ញៀវនៃអ្នកប្រាជ្ញ និងមន្ត្រីរដ្ឋបាលផ្សេងៗរបស់ហូឡង់ដ៏។ អ្នកទាំងនោះបានអញ្ជើញពពួកអាចារ្យ (padanda) នៅលើកោះឱ្យមកជួបគាត់។ គេសួរទៅអាចារ្យទាំងនោះថា តើមានស្គាល់ ឬបានរក្សាទុកនូវសំណេរបុរាណដែលមិនយល់ទេ? បន្តិចក្រោយមក អាចារ្យទាំងនោះទៅយកគម្ពីរមួយចំនួនហើយអានឱ្យលោក Sylvain Lévi ស្ដាប់។ អត្ថបទទាំងនោះពិតជាអត្ថបទសំស្ក្រឹតមែន ក៏ប៉ុន្តែខុសច្រើន ហើយអាចារ្យទាំងនោះអានមិនច្បាស់ថែមទៀត។ ទោះជាយ៉ាងណាក៏លោក Sylvain Lévi យល់ភ្លាមថានោះពិតជាធម៌ចាស់ដែលគាត់ខ្លួនឯងចាំស្ទាត់។ គាត់ក៏សូត្រធម៌នោះឱ្យពពួកអាចារ្យស្ដាប់វិញ។ ពេលនោះ អាចារ្យម្នាក់ដែលមានវ័យចំណាស់ជាងគេនៅចាំថា

---

* ដកស្រង់ពី *Comptes-Rendus de l'Académie des Inscriptions et Belles-Lettres*, Paris, janvier-mars 1968, pp. 72-81។ ប្រែសម្រួលដោយ ស៊ីយ៉ុន សុភារិទ្ធ។

គ្រូរបស់គាត់ធ្លាប់សូត្រធម៌ដូចដែលលោក Sylvain Lévi ទើបនឹងសូត្រអម្បាញ់មិញនេះដែរ។ អាចារ្យទាំងអស់ក៏ប្តូរយោបល់គ្នា ហើយជឿស្របគ្នាថា ហេតុដែលនាំឲ្យពិធីដែលធ្លាប់ធ្វើកន្លងមកពុំសូវមានប្រសិទ្ធភាពនោះ គឺមកពីការថ្លង់ឃ្លាតឆ្ងាយពីគម្ពីរដើមនោះហើយ។ ពួកគាត់សង្ឃឹមថា លោក Sylvain Lévi អាចជួយកែតម្រូវក្បួនទាំងនោះឡើងវិញ។ អាចារ្យទាំងនោះក៏ទៅយកក្បួនដែលបានចម្លងដៃទុកក្នុងសៀវភៅជាអក្សរ Bali មកឲ្យលោក Sylvain Lévi។ ក្នុងចំណោមសៀវភៅទាំងនោះ សព្វថ្ងៃមានប្រាំក្បាលជាកម្មសិទ្ធនៃវិទ្យាស្ថានអារ្យធម៌ឥណ្ឌា នៅក្នុងបណ្ណាល័យ Sylvain Lévi។

ក្នុងការបោះពុម្ពឲ្យបានត្រឹមត្រូវឡើងវិញ លោក Sylvain Lévi ពិនិត្យឃើញថាមានសម្រង់គម្ពីរវេទជាកំណាត់ៗ ឯភាគឯទៀតគឺជាពាក្យសូត្រសសើរលើកតម្កើងទេពផ្សេងៗនៃសាសនាហិណ្ឌូសម័យកណ្តាល និងសម័យថ្មី។ មានផ្នែកខ្លះជាសម្រង់គម្ពីរព្រះពុទ្ធសាសនាផង។ រីឯមួយផ្នែកធំ ឃ្លាតចាកច្បាប់ដើមឆ្ងាយពេក ក៏មើលលែងយល់នឹងរកប្រភពមិនឃើញ។ ប៉ុន្តែបើពោលជាទូទៅ ក្បួនទាំងមូលនោះមិនបាត់បង់ទៅណាឡើយ ដោយសារកន្លែងខ្លះដែលមានខ្វះ គេអាចយកទៅប្រៀបធៀបនឹងឯកសារផ្សេងៗទៀត។

មិនតែប៉ុណ្ណោះ មានគម្ពីរជាភាសាសំស្ក្រឹតដែលរៀបរាប់អំពីពិធីផ្សេងៗ ហើយដែលតែងមានអត្ថាធិប្បាយជាភាសា Bali ទៀតផង។ គម្ពីរទាំងនោះ មួយផ្នែករក្សាទុកនៅបណ្ណាល័យនៃសាកលវិទ្យាល័យ Leiden ហើយចាប់ពីឆ្នាំ១៩២៨មក គេប្រើនប្រមូលទុកនៅបណ្ណាល័យពិសេសមួយឈ្មោះ Gedong Kirtya ស្ថិតនៅក្រុង Singaraja ប៉ែកខាងជើងកោះ Bali។ ក្រៅពីនោះ អ្នកស្រាវជ្រាវអាចធ្វើការសាកសួរពពួកអាចារ្យអំពីន័យនៃពិធីផ្សេងៗដែលគេតែងប្រារព្ធ ហើយថែមទាំងអាចចុះទៅសង្កេតការផ្ទាល់ផង។ លោកសាស្ត្រាចារ្យ C. Hooykaas ដែលជាអ្នកប្រាជ្ញសិក្សា Bali ជាងសាមសិបឆ្នាំមកហើយនោះ កំពុងសិក្សាអត្ថបទទាំងនោះផង និងសង្កេតតាមដានពិធីផ្ទាល់ផង។ ប៉ុន្មានឆ្នាំមកនេះ លោកបានផ្សាយនូវស្នាដៃពីរ។ ទីមួយឈ្មោះ*Agama Tirtha* (Amsterdam, 1964) ឯមួយទៀតឈ្មោះ*Surya-sevana* (Amsterdam, 1966)។ តាមរយៈសំណៅទាំងពីរនេះ គេអាចដឹងអំពីប្រវត្តិការស្រាវជ្រាវព្រមទាំងឯកសារនានាដែលមានមុននិងក្រោយការផ្សព្វផ្សាយរបស់លោក Sylvain Lévi។

ឯយើងវិញ យើងអាចចូលរួមចំណែកក្នុងការសិក្សានេះ ដោយធ្វើការស្រាវជ្រាវតាមប្រភពឥណ្ឌាដែលផ្តល់នូវប្រយោជន៍ពីរ៖ ទីមួយគឺឲ្យយើងមុជជ្រៅទៅក្នុងសាសនានៃប្រទេសឥណ្ឌា មួយទៀតជាមធ្យោបាយឲ្យយើងយល់ពីវិសាលភាពនៃការផ្សព្វផ្សាយឥទ្ធិពលឥណ្ឌាមកបូព៌ាប្រទេស។

ការមុជជ្រៅដើម្បីបង្កើនចំណេះដឹងអំពីសាសនាឥណ្ឌា ត្រូវតែធ្វើឡើងជាធម្មតា។ វិជ្ជាអំពីឥណ្ឌាសម័យបុរាណរីកចំរើនខ្លាំងនៅអឺរ៉ុប ពោលគឺនៅឆ្ងាយពីទឹកដីដើម ដែលនៅតែមានអារ្យធម៌រស់រវើក។ ដូច្នេះការសិក្សា ធ្វើឡើងផ្តោតលើឯកសារចាស់ បើពុំនោះទេផ្តោតលើប្រពៃណីទូទៅដែលបណ្ឌិតផ្សេងៗជាតិឥណ្ឌាសព្វថ្ងៃនៅស្គាល់និងរក្សាទុក។

ឯកសារដែលចាស់ជាងគេមានគម្ពីរវេទជាដើម ទាក់ទាញអារម្មណ៍អ្នកស្រាវជ្រាវខ្លាំងជាងគេ ហើយគេចាត់ទុកជាមូលដ្ឋានមួយនៃអារ្យធម៌ក្រោយៗមកទៀត។ ទាំងភាសា ទាំងសេចក្តីនៃគម្ពីរវេទ សុទ្ធសឹងគេយកមកប្រៀបធៀបជាមួយវប្បធម៌បុរាណនៅអឺរ៉ុប និងនៅអ៊ីរ៉ង់ទៀតផង។ គម្ពីរវេទមានកិត្តិនាមខ្ទរខ្ទាយខ្លាំងណាស់។ ក្នុងវប្បធម៌ឥណ្ឌាគ្រប់សម័យកាល គេតែងមានឃើញស្លាកស្នាម និងចំណុចច្រើនដែលទាក់ទងនឹងសាសនាវេទ។ ប៉ុន្តែសាសនាវេទនេះមិនដែលបានរីកសាយភាយពេញទូទាំងប្រទេសឥណ្ឌាសោះ។ ម្យ៉ាងទៀតសាសនានេះក៏បាត់បង់ប្រមាណពីរពាន់ឆ្នាំមកហើយ។ ទោះជាដូច្នេះក្តី ក៏ការសូត្រគម្ពីរវេទនៅមានរហូតដល់សព្វថ្ងៃ។

ការសូត្រនោះពុំមែនឥតប្រយោជន៍ទេ ត្បិតជាការហាត់រៀនផ្លូវចិត្តឲ្យជ្រួតជ្រាបនូវពាក្យពេចន៍ ដែលគេយល់ថាជាទីសក្ការៈបំផុត ហើយទម្លាប់ដុះខាត់ស្មារតីឲ្យមានការចងចាំព្រមទាំងវាងវៃផង។ ប៉ុន្តែការសូត្រធម៌វេទពុំជះឥទ្ធិពលអ្វីទៅលើគំនិតនិងកិច្ចប្រតិបត្តិសាសនាឡើយ ព្រោះគំនិតនិងការប្រព្រឹត្តិនោះ ផ្អែកមូលដ្ឋានលើការបកស្រាយគម្ពីរវេទដែលកើតនៅសម័យកណ្តាលទៅហើយ ព្រមទាំងលើចលនាជំនឿផ្សេងអំពីនោះទៀត។ តាមពិតទៅ សាសនាបានវិវឌ្ឍន៍ឆ្ងាយមកហើយ ដោយឥទ្ធិពលហូរចូលមកជាយូរតាមពិធីផ្សេងៗដែលកើតឡើងនៅមជ្ឈដ្ឋានព្រាហ្មណ៍គោរពគម្ពីរវេទ។ នាបច្ចុប្បន្ននេះ ក្បួន តម្រា គម្ពីរនានា ដែលជាគោលនៃកិច្ចប្រតិបត្តិសាសនានៅប្រទេសឥណ្ឌាគឺ “អាគម” និង “តន្ត្រ”។ គម្ពីរទាំងនេះរៀបរៀងឡើងជាភាសាសំស្ក្រឹត។ គេច្រើនរក្សាទុកនៅប្រទេសឥណ្ឌាខាងត្បូង ពោលគឺតំបន់ទមិឡ។ ប្រភពទមិឡនេះឲ្យយើងដឹងថាកិច្ចប្រតិបត្តិសាសនានោះមានតាំងតែពី៤០០ឆ្នាំ មុនគ្រឹស្តសករាជម្ល៉េះ ក្នុងនោះធម៌វេទមាននាទីសំខាន់។ ប៉ុន្តែសាសនិកច្រើនគិតថា គម្ពីរវេទ

ផ្តល់មកនូវការសោយសុខ (ភុក្តិ) មួយមុខប៉ុណ្ណោះ ចំណែកឯក្បួន "អាគម" វិញអាចនាំមកនូវការសោយសុខផង និងការរំដោះ (មុក្តិ) ផុតវដ្តសង្សារផង។

នៅអឺរ៉ុប ការសិក្សាអំពីឥណ្ឌាសម័យបុរាណផ្តោតខ្លាំងទៅលើការប្រតិបត្តិសាសនាវេទ និងសាសនាព្រាហ្មណ៍។ ការសិក្សានោះត្រូវតែមុជជ្រៅថែមទៀត។ ប៉ុន្តែគេពុំទាន់បានសិក្សាអំពីគម្ពីរ "អាគម" សោះ។ បើពិនិត្យមើលសាសនាដែលគេគោរពនៅឥណ្ឌាសម័យបច្ចុប្បន្ន យើងឃើញថាឥទ្ធិពលអាគមនេះចាក់ឫសជ្រៅ។ ម្យ៉ាងទៀតអារ្យធម៌ឥណ្ឌាដែលចាប់ផ្តើមហូរចូលទៅឥណ្ឌូចិន និងឥណ្ឌូណេស៊ីពីបុរាណកាលនោះ ក៏មានឥទ្ធិពលអាគមខ្លាំងនៅក្នុងសាសនាដែរ គឺហូរចូលព្រមគ្នានឹងវិស័យដទៃទៀត មានទេវកថាធំៗ, កាព្យសាស្រ្ត, ហោរាសាស្រ្ត, វិជ្ជាពេទ្យជាដើម។ រីឯសាសនាវេទជំនាន់នោះ គឺសាបរលាបអស់ទៅហើយ។ គំនិតឬទ្រឹស្តីធំៗនៃអាគមនេះឯង ដែលជាគោលសំខាន់នៃការកសាងប្រាសាទ និងជាមូលដ្ឋាននៃជំនឿលើទេពទាំងពួង។ អាស្រ័យហេតុនេះហើយបានជានៅ Pondichéry យើងខ្ញុំខិតខំស្រាវជ្រាវបកស្រាយ ធ្វើអត្ថាធិប្បាយ ព្រមទាំងផ្សព្វផ្សាយអត្ថបទគម្ពីរទាំងនោះ។

នៅកោះ Bali ពាក្យ "អាគម" សំដៅលើ "សាសនា"។ បើន័យសំស្រ្កឹតដើមវិញគឺ "ប្រពៃណី"។ សព្វថ្ងៃគេពោលថា Agama Hindu Bali ("សាសនាហិណ្ឌូនៅកោះ Bali") ដើម្បីសំដៅទៅលើប្រព័ន្ធសាសនាដែលគេពេញគោរពប្រតិបត្តិ។ គឺ "អាគម" នេះឯងហើយដែលនៅទីនេះជាមូលដ្ឋាននៃពិធី និងគម្ពីរនានា ទាំងហិណ្ឌូផង ទាំងខាងពុទ្ធសាសនាផង។ ប៉ុន្តែការបត់បែនទៅតាមទេសកាលមានមែនពិត។ ខ្ញុំនឹងបង្ហាញឧទាហរណ៍មួយតាមរយៈការសិក្សាអំពីពិធីបូជាសពដូចតទៅ៖

ខ្ញុំធ្លាប់បានស្នាក់នៅរយៈពេលខ្លីចំនួនពីរដងនៅកោះ Bali ។ លើកទីមួយជាមួយលោក Louis-Charles Damais (ធ្វើអនិច្ចកម្មទៅហើយ) លើកទីពីរជាមួយលោក Denys Lombard ដែលជាសិស្សគាត់ ហើយដែលបានទទួលដំណែងបន្តពីគាត់នៅមណ្ឌលស្រាវជ្រាវនៃសាលាបារាំងចុងបូព៌ា នៅឥណ្ឌូណេស៊ី។ ក្នុងឱកាសនោះ ខ្ញុំបានទៅមើលបុណ្យសពផ្សេងៗដែលមានភាពអធិកអធំក្រៃលែង។ ក្នុងពេលស្នាក់នៅលើកទីពីរនាខែកក្កដា_សីហាកន្លងទៅ[7] លោកសាស្រ្តាចារ្យ Hooykaas ដែលជាអ្នកធ្លាប់សិក្សាស្រាវជ្រាវរឿងអស់ទាំងនេះ មានសណ្តានចិត្តល្អជួយផ្តល់ការពន្យល់ជាច្រើនមកខ្ញុំ។ ម្យ៉ាងវិញទៀត ពិធីប្រភេទនេះធ្លាប់មានការស្រាវជ្រាវពីមុនៗមកដែរ លើកក្រោយបំផុតពីសំណាក់អ្នកស្រី Jeanne Cuisinier (ធ្វើអនិច្ចកម្មទៅហើយ) ដែលបានបរិយាយនៅឆ្នាំ១៩៦២ ក្នុងទស្សនាវដ្តី *France-Asie* អំពីកិច្ចបូជាសពក្សត្រតំបន់ Bangli កាលពីខែសីហាឆ្នាំ១៩៦១។ មុនលោកស្រីទទួលអនិច្ចកម្ម ទស្សនាវដ្តី *Bulletin de l'École Française d'Extrême-Orient* បានចុះអត្ថបទលោកស្រីមួយនៅឆ្នាំ១៩៦៥ ឈ្មោះថា Le Rituel familial à Bali ដែលក្នុងនោះមានការសិក្សាអំពីពិធីបូជាសពនៅ Bali ដែរ។ លុះខ្ញុំអានអត្ថបទទាំងអស់នោះទៅ ខ្ញុំឃើញថាជាទូទៅពិធីដែលខ្ញុំបានសង្កេតមើល ពុំខុសអ្វីប្លែកពីពិធីដែលគេបានស្រាវជ្រាវហើយទេ។ ប៉ុន្តែបើយកឯកសារបុរាណជាភាសាសំស្រ្កឹត ព្រមទាំងពីធីដទៃទៀតនៅប្រទេសឥណ្ឌា និងនៅកម្ពុជាមកជួយបំភ្លឺផង ការសិក្សានេះអាចនឹងមុជជ្រៅទៅមុខបានមួយកម្រិតទៀត។

នៅឥណ្ឌា គេនិយមបូជាសពភ្លាមៗ ពោលគឺមិនយូរប៉ុន្មានក្រោយពីបុគ្គលចែកស្ថានទៅ ហើយពុំមានពិធីអធិកអធំវែងឆ្ងាយទេ។ ឯនៅ Bali វិញ ជាពិសេសចំពោះគ្រួសារអ្នកមានធនធានច្រើន គេតម្កល់សពរាប់ខែដោយមានពិធីគ្រឹកគ្រេងកំដររហូត។ នៅឥណ្ឌា ទាំងគម្ពីរ "អាគម" ក៏មានចែងទាំងការប្រព្រឹត្តជាក់ស្តែងក៏ធ្វើស្របគ្នា គឺថាគេដាក់សពឲ្យអង្គុយឬដេកនៅលើគ្រែស្នែងមួយដែលគ្របដណ្តប់ដោយផ្កា ទើបគេហែរទៅទីបូជាដោយមានក្បួនតន្រ្តីប្រគុំកំដរជាមួយផង។ ពេលទៅដល់ គេដាក់សពលើគំនរអុស ជាមួយគ្រឿងតង្វាយនិងវត្ថុខ្លះដែលសពនោះធ្លាប់ប្រើប្រាស់កាលពីនៅរស់។ លុះដុតរួច គេប្រមូលកំទេចធាតុនិងផេះទៅបោលនៅកន្លែងមុជទឹកជាទីសក្ការៈណាមួយ ដែលអាចហូរទៅដល់សមុទ្របាន ហើយដែលគេសន្មតឧបកិច្ចថាជាទន្លេគង្គា។ កិច្ចប្រព្រឹត្តនេះ វៀរលែងតែចំពោះតាបស (យតិ) ឬចំពោះអ្នកដែលបានសម្រេចធម៌ហើយបានឆ្លងពិធីផ្តល់ភាពសក្ការៈ (ទីក្សា) គេឯងទទួលស្គាល់ថាអត្ថិ៍នរបស់ខ្លួនផ្សាភ្ជាប់ទៅព្រះឥសូរ។ អ្នកជំពូកនេះគេពុំដុតឡើយ ព្រោះគេសន្មតថាភ្លើងនៃពិធីទីក្សាបានជម្រះមន្ទិលស្រឡះពីប្រាណអស់រួចទៅហើយ ដូច្នេះគ្រាន់តែយកសពនោះទៅកប់ក្នុងរណ្តៅមួយ។ នៅពីលើនោះ គេយល់ថាគប្បីពូនផ្នូរឡើង ហើយតម្កល់លិង្គមួយស្នងឲ្យព្រះឥសូរ សន្មតទីនោះហៅថា "សមាធិ"។ នៅជុំវិញ "សមាធិ" នេះ គប្បីកសាងឲ្យទៅជាមណ្ឌលនៃទីបូជាមួយ។ កិច្ចអស់ទាំងនេះ បើធ្វើបានជាការប្រសើរ តែពុំមែនជាការចាំបាច់ខានមិនបានឡើយ។

---

[7] កំណត់អ្នកប្រែ៖ ឆ្នាំ១៩៦៧។

នៅកោះ Bali ពិធីបូជាសពប្រព្រឹត្តទៅប្រហាក់ប្រហែលគ្នានឹងនៅឥណ្ឌាដែរ បើមើលលើគោលការណ៍ធំៗទូទៅ។ ចំពោះចំណុចដែលខុសគ្នាវិញ គួរយើងវិភាគញែកឲ្យដាច់ឃើញថា អ្វីដែលចម្លងមកពីប្រពៃណីឥណ្ឌានានា អ្វីដែលជាជំនឿមូលដ្ឋានផ្ទាល់នៃជនជាតិកោះឥណ្ឌូណេស៊ី អ្វីទៀតដែលជាការបង្កើតថ្មី ហើយការបង្កើតនោះធ្វើឡើងក្នុងទេសកាលអ្វីផង។

ពិធីសំខាន់ដែលខ្ញុំបានតាមដាន ធ្វើឡើងនាថ្ងៃទី២សីហា១៩៦៧ នៅ Ubud ពោលគឺនៅចំកណ្ដាលកោះ Bali តែម្ដង។ ត្រកូលដែលពាក់ព័ន្ធនោះ គឺត្រកូលក្សត្រ Cokorda Gde NGurah និង Gde Raka Sukawati។ ក្សត្រទីពីរនេះធ្លាប់បាននាំក្រុមរបាំដ៏ល្បីនៃ Bali ទៅសម្ដែងនៅក្រុងប៉ារីស៍កាលពីឆ្នាំ១៩៣១។ម្យ៉ាងទៀតគាត់ធ្លាប់ជាអ្នកផ្ដល់ពត៌មានឲ្យអ្នកស្រី Jeanne Cuisinier ក្នុងការស្រាវជ្រាវផង។ គាត់ស្លាប់នៅខែមករាឆ្នាំ១៩៦៧។

នៅ Bali សពអភិជនគេតែងលាបលននិងបញ្ចូលវត្ថុធាតុផ្សេងៗមានគ្រឿងក្រអូបជាដើម ដើម្បីទុកតម្កល់ក្នុងម្ឈូសបានយូរ។ បើសពសាមញ្ញគេកប់ភ្លាមៗ ហើយថ្ងៃក្រោយទើបគាសវិញ។

សព្វថ្ងៃនេះ ដើម្បីរក្សាសពបានយូរ គេឲ្យពេទ្យមកចាក់ថ្នាំ។ ប៉ុន្មានថ្ងៃមុនដុត គេបញ្ជូនសពនោះមកតម្កល់ក្នុងរោងពិសេសមួយនៃ puri ពោលគឺតំណាក់នៃក្សត្រក្នុងតំបន់ណាមួយដែលសពនោះនឹងត្រូវបូជា។ តំណាក់នោះជាលំនៅនៃអភិជន (satriya, មកពីសំស្ក្រឹត kṣatriya) មានកំពែងពាត់ជុំវិញ ហើយមានអាគារសម្រាប់រស់នៅ និងសម្រាប់បម្រើការងារផ្សេងៗ ព្រមទាំងមានប្រាសាទសម្រាប់កិច្ចបូជាមួយផង ហៅថា pura សម្រាប់បូជាទេពនិងបុព្វការីជន។ រោងពិសេសតម្កល់សពដែលហៅថា sumanggen ស្ថិតនៅក្នុងតំណាក់នេះ។

ក្នុងពិធីសពដែលខ្ញុំបានឃើញនៅ Ubud នាថ្ងៃទី២៩កក្កដា ពោលគឺប្រាំថ្ងៃមុននឹងបូជា គេយកសពនៃក្សត្រទាំងពីរមកតម្កល់នៅ sumanggen។ ចាប់អំពីនោះមករហូតដល់ថ្ងៃបញ្ចប់ គេថ្វាយតង្វាយផ្សេងៗ រាប់បញ្ចូលទាំងភ្លេងនិងរបាំផង។

លុះស្អែកឡើង គេធ្វើដង្ហែរ nagabanda ចាប់តាំងពីភូមិដែលគេរៀបចំរចនាមកនោះរហូតដល់រោងតម្កល់សពនៃក្រុង Ubud។ Nagabanda នេះជានាគដែលគេក្រងអំពីឫស្សី ពាសទៅដោយក្រណាត់កម្ពីក្រហម និងក្រដាសពណ៌ទឹកមាស។ តាមពិតទៅ គឺកំណាត់នៅខាងក្បាល និងកំណាត់នៅខាងកន្ទុយប៉ុណ្ណោះ ដែលក្រងលំអរបៀបនេះ ចំណែកឯមួយភាគនៅកណ្ដាលខ្លួន គឺជាក្រណាត់ដ៏វែងមួយ។ អ្នកស្រីJeanne Cuisinier ធ្លាប់សង្កេតឃើញថា អ្នកស្រុកធ្វើការបកស្រាយប្លែកៗគ្នាអំពីនិមិត្តរូបនៃនាគនេះ។ ន័យមួយដែលស្របគ្នា គឺនាគនេះមានទំនាក់ទំនងទៅនឹងធាតុទឹក។ នេះក៏ពុំប្លែកអ្វីដែរ ត្បិតនៅឥណ្ឌា សត្វនាគនិងទឹកមានទំនាក់ទំនងគ្នាខ្លាំងដូច្នេះឯង។ បើនៅរដ្ឋ Kashmir ផង ឈ្មោះភូមិស្រុកដែលហៅថា “នាគ” មានន័យថា “ប្រភពទឹក”។ ប៉ុន្តែនៅ Bali វិញ nagabanda មាននាទីដឹកនាំអ្នកស្លាប់ទៅដល់ទីបូជា ហើយត្រូវគេដុតជាមួយសពនោះដែរ គឺមានន័យថាភ្ជាប់ខ្លួនទៅនឹងសពនោះរហូតដល់បរលោក។

នៅ Ubud មាន nagabanda មួយនោះ គេដាក់លើគ្រែស្នែងមួយ ដង្ហែរយកតាំពីក្រុង Gianyar មក (ក្រុងនេះកាលជំនាន់មុនជាមណ្ឌលនៃអាណាចក្រមួយដែលគ្រប់ដណ្ដប់លើ Ubud ដែរ)។ អ្នកដែលទទួលបន្ទុកនាំក្បួនហែរ ហើយអង្គុយលើគ្រែស្នែងជាមួយគ្នានោះ គឺក្សត្រាដែលតពូជពីស្ដេចគ្រប់គ្រងពីជំនាន់មុននោះឯង។ សមណសក្ដិនៃក្សត្រានោះ គឺ deva agung មានន័យថា “មហាក្សត្រ”។ ពិធីហែរនេះមានឥទ្ធិពលផ្នែកនយោបាយដែរ ជាពិសេសក្នុងមជ្ឈដ្ឋានអភិជន ត្បិតក្សត្រានោះចុះតពូជត្រង់មកពីរាជវង្សដែលពួកហូឡង់ដ៏បានរំលាយរាជបល្ល័ង្កចោលនៅឆ្នាំ១៩០៨ ហើយដែលសាធារណរដ្ឋឥណ្ឌូណេស៊ីពេលដែលកកើតឡើង ក៏ប្រានឲ្យនៅឆ្ងាយពីការគ្រប់គ្រងស្រុកទៀត។

Nagabanda ទាំងអស់ គេដង្ហែរចូលតំណាក់ក្រុង Ubud នៅថ្ងៃ២៩កក្កដា បន្ទាប់មកគេដង្ហែរចេញពីទីនោះវិញនៅថ្ងៃទី៣០ ដើម្បីយកទៅប្រសិទ្ធីនៅទីកន្លែងមួយផ្សេង រួចទើបគេយកត្រឡប់មកតំណាក់វិញ។ ថ្ងៃដដែលនោះ មនុស្សម្នាយកតង្វាយមកគគ្រឹកគគ្រេង ដោយមានអាចារ្យធំម្នាក់ជាអ្នកទទួល។ នៅថ្ងៃ៣១កក្កដា និង១សីហា ក៏នៅតែមានតង្វាយនាំចូលមកពុំដាច់។ ជារាល់ថ្ងៃ គេតែងឃើញក្បួនយាត្រាមួយដែលហែរទៅរកទឹកបរិសុទ្ធសម្រាប់យកមកប្រើក្នុងការប្រោះព្រំ។ ឯតន្ត្រីនិងរបាំក៏មានប្រគំរាល់ថ្ងៃនៅក្នុងតំណាក់នោះដែរ។ ថ្ងៃ១សីហា រណ្ដាប់ធំតូចដែលចាំបាច់ក្នុងការដង្ហែរសព ព្រមទាំងសំណង់សម្រាប់ពេលស្អែកឡើង ឃើញថារៀបចំហើយស្រេច។ ប៉មមួយធំខ្ពស់ត្រដែត ធ្វើអំពីឫស្សីនិងរុក្ខជាតិផ្សេងទៀត ក៏ធ្វើឡើងស្រេចដែរ។ ក្នុងនោះ សពទាំងពីរនឹងត្រូវដាក់ទៅក្នុងបន្ទប់មួយធ្វើខ្ពស់ផុតពីដី១២ម ហើយដែលមានកំពូលស្រួចទៅលើតាមថ្នាក់ៗជាន់លើគ្នា ស្នងឲ្យភ្នំព្រះសុមេរុ ដែលជាភ្នំស្នូលកណ្ដាលនៃលោក។ កំពស់ទាំងស្រុងពីដីទៅដល់កំពូលមានជាង២០ម។ ដើម្បីនឹងយោងសពទៅតម្កល់ក្នុងបន្ទប់នោះ គេត្រូវរៀបក្ដារផ្ដេកបន្តិចដើម្បីរំកិលបាន។ ចំណោតក្ដារនោះត្រូវខ្សោយ ដូច្នេះក្ដារផ្ដេកចុះមកដល់ដី ដោយឆ្លងលើ

កំពែងតំណាក់ចេញមកក្រៅទៀត។ គេតម្លើងក្ការផ្ដេករបៀបនេះមួយទៀត ទុកនៅកន្លែងដុតសពខាងក្រោយភ្នំយោង ដែលគេសង់នៅមុខ ប្រាសាទ។

មុនបូជាមួយថ្ងៃ គឺជាពេលដែលមនុស្សកកកុញខ្លាំងមករួមក្នុងការកំសាន្តនានា មានទស្សនីយភាព តូរ្យតន្ត្រី មានគេលក់ចំណីចំណុក គ្រប់បែបយ៉ាង ព្រោះពិធីបូជាសពជាការជម្រះមន្ទិល ធ្វើឱ្យសពទៅកាន់សួគ៌នាយ ពុំមែនជាការសោកសង្រេងឡើយ។

ជុំវិញសពនីមួយៗ សុទ្ធសឹងជាតង្វាយ មានទាំងក្បាលក្របីមួយ ដែលទើបតែសម្លាប់ហើយថ្មីៗផង។ សម្រាប់សពនីមួយៗ គឺគេសម្លាប់ក្របីមួយ។ ទំនៀមនេះឥតមានចម្លងពីប្រពៃណីឥណ្ឌាឡើយ គឺជាទំនៀមដែលឥណ្ឌូណេស៊ីមានតាំងពីបុរាណកាលមក។ នៅតំបន់ដទៃទៀតនៃឥណ្ឌូណេស៊ី ក៏គេនៅកាប់ក្របីដែរក្នុងពិធីបូជាសព ជាពិសេសជនជាតិ Toraja នៃកោះ Sulawesi ដែលដាច់ឥទ្ធិពលពីឥណ្ឌា។ សូម្បីតែនៅកោះជ្វា ដែលកាន់សាសនាឥស្លាមក៏គេឃើញមានស្លាកស្លាមទំនៀមនេះដែរ យ៉ាងហោចណាស់យើងស្មានដឹងបានតាមភាសា (សូមអាន L. Ch. Damais, *BEFEO*, XLVIII, p.359)។ ទំនៀមបូជាក្របីមានដែរនៅឥណ្ឌា ប៉ុន្តែគេធ្វើឡើងដើម្បីឧទ្ទិសទៅព្រះនាងទុគ៌ា ក្រៅពីនេះគេឃើញមាននៅជនជាតិផ្សេងៗ ដូចជាពួក Toda ជាដើម ដែលពុំមានទទួលឥទ្ធិពលណាក្រៅពីឥណ្ឌា។

ទោះជាយ៉ាងណាក៏ដោយយើងគួរចោទសួរថា ហេតុអ្វីក៏នៅកោះ Bali ដែលទទួលឥទ្ធិពលខ្លាំងក្លាពីឥណ្ឌា គេប្រកាន់ទំនៀមចាស់ដែលមានតាំងពីមុនសាសនាហិណ្ឌូចូលមកទៅទៀត។ បើយើងឆ្លើយថា មកពីទំនៀមនោះចាក់ឫសខ្លាំងទៅក្នុងប្រពៃណីតែប៉ុណ្ណោះពុំគ្រប់គ្រាន់ឡើយ។ យើងត្រូវដឹងថាព្រះនាងទុគ៌ា ដែលជាទេពីសម្លាប់អសោរក្របី (មហិសាសុរមទ៌នី) គេធ្លាប់គោរពបូជាទូទៅនៅកោះនេះពីមុនមក ដូចមានភស្តុតាងរាប់ពុំអស់តាមរូបចម្លាក់នានា។ ទំនៀមកាប់ក្របីពេលបុណ្យសពនេះ ប្រហែលជាធ្លាប់ធ្វើក្នុងមជ្ឈដ្ឋានហិណ្ឌូនៅកោះ Bali នេះផង ដោយគេធ្វើការបកស្រាយអត្ថន័យតាមទេវកថាហិណ្ឌូនោះ។ ម្យ៉ាងទៀតគួរគិតថា ទោះជានៅក្នុងពិធីហិណ្ឌូ ក៏គេអាចអនុញ្ញាតិឱ្យបញ្ចូលការកាប់ក្របីដែរ។ ពិតមែនតែគម្ពី "អាគម" ពុំមានចែង ប៉ុន្តែគម្ពីនេះក៏អាចរាប់បញ្ចូលទំនៀមវេទ ព្រោះគេដឹងថាមានពាក្យសូត្រវេទផ្សេងៗក្នុងនោះ។ អ្នកប្រាជ្ញបណ្ឌិតនានាដឹងអំពីបញ្ហានេះ។ ថ្វីត្បិតតែអស់លោកទាំងនោះមិនទទួលស្គាល់ជាផ្លូវការ ក៏គេមិនទាត់ចោលការលាយឡំគ្នានេះដែរ។ មានគម្ពីរដែលចែងថាការសម្លាប់សត្វបូជាក្នុងបុណ្យសពជួយឱ្យអ្នកស្លាប់ទៅចាប់ជាតិនៅស្ថានជាទីគប្បី ពោលគឺស្ថាននៃក្រុមបិតរ រីឯពិធីបូជាសពនៅ Bali ក៏មានឈ្មោះថា Pitrayajña (បិតរយជ្ញ) ដែរ។ មិនតែប៉ុណ្ណោះគម្ពីរ "កៅសិកសូត្រ" (81, 20 sq.) មានចែងបង្គាប់ឱ្យសម្លាប់គោញីមួយហើយយកក្រលៀនមកដាក់ក្នុងដៃនីមួយៗនៃសព។ គោនោះ គេកាត់យកជើងទាំងបួន មកគ្របតណ្ដប់លើដៃជើងនៃសព ទើបគេយកក្បួន "អថវវេទ"[២] (XVIII, 2, 11= *RV*, x, 14, 10) មកសូត្រត្រង់ចំណុចដែលគេតឿនរន្ទើនអ្នកស្លាប់នោះឱ្យរត់លឿនជាងឆ្កែដែលនៅចាំយាមស្ថានពួកបិតរ ត្បិតអ្នកស្លាប់ត្រូវទៅសោយសុខនៅស្ថាននោះឯង។ សាច់ដែលគេដាក់លើជើងដៃអ្នកស្លាប់ ប្រហែលជាសម្រាប់ទាក់ទាញឱ្យឆ្កែរវល់តែត្របាក់ស៊ីដើម្បីឱ្យខ្មោចនោះរត់ផុត។ ប្រការនេះ ពុំមែនមានចែងតែក្នុងគម្ពីរកៅសិកសូត្រប៉ុណ្ណោះទេ គឺមាននៅគម្ពីរផ្សេងៗទៀតនៃសាសនាវេទ (សូមអាន P. V. Kane, *History of Dharmaśśātra*, IV, 206)។ អស់អ្នកប្រាជ្ញបណ្ឌិតខាងពិធីតែងតែស្គាល់។ ទោះបីជាអស់លោកនោះមិនអនុវត្តន៍ផ្ទាល់ ក៏លោកចាត់ទុកថាស្របតាមគន្លងក្រឹត្យក្រមដែរសម្រាប់ទេសកាលខ្លះៗ វៀរលែងតែអនុវត្តន៍ក្នុងសម័យកលីយុគ ឬនៅមជ្ឈដ្ឋានអ្នកតឹងរ៉ឹង។ បើគេបញ្ញាត្តិឱ្យធ្វើកិច្ចបូជាគោញីដូច្នេះហើយ គ្មានអ្វីគួរឱ្យចម្លែងទេថាអាចទទួលស្គាល់ការបូជាក្របី ដែលធ្លាប់ប្រព្រឹត្តិមកយូរលង់ក្នុងប្រពៃណីអ្នកស្រុក ថាមិននាំមកនូវភាពគ្រោះថ្នាក់អ្វីខ្លាំងមកលើក្បួនខ្នាត ដែលមានចែងនៅគម្ពីរអាគម។

មុនពេលដែលគេសង់រថបុស្បកសម្រាប់ដឹកសពនោះទៅទៀត គេធ្វើរូបគោអំពីឈើដែលមានក្រណាត់ខ្មៅរំលេចទៅដោយក្រដាសពណ៌ទឹកមាសបិតពីលើ។ រូបគោមួយប្រើសម្រាប់ដុតសពមួយ។ បើនៅឥណ្ឌា គេដាក់សពផ្ទាល់លើគំនរអុស។ នៅទីនេះវិញពុំដូច្នេះឡើយ សពត្រូវបញ្ចុះទៅក្នុងរូបសត្វមួយ ដែលគេលុងខ្លួនឱ្យខូង (ហាក់ដូចជាម្ឈូសដែរ) រីឯរណ្ដាប់តង្វាយនិងអុសដុត គេគរជុំវិញនិងក្រោមពោះសត្វនោះ។ Nagabanda គឺគេដាក់នៅជិតរូបសត្វ។ ទាំងអស់នេះស្ថិតនៅក្នុងភ្នំយោងមួយ ដែលនឹងត្រូវដុតឆេះសុះជាមួយអ្វីៗទាំងអស់។ ក្សត្រានៅកោះ Bangli ត្រូវបានគេបូជានៅក្នុងសត្វសិង្ហ ពុំមែនគោទេ។ ប៉ុន្តែរូបគោ គេនិយមប្រើជាងគេក្នុងការបូជាសពព្រាហ្មណ៍ មិនតែប៉ុណ្ណោះក្នុងការបូជាពួកក្សត្រទៀតផង ដូចជានៅ Ubud នេះជាដើម។ រូបគោច្រើនតែពណ៌ខ្មៅ ប៉ុន្តែម្ដងៗមានពណ៌ផ្សេងៗដែរ។ យើងធ្លាប់បានឃើញរូបគោសមួយប៉ុនកូនគោមែនទែន តែឥតក្បាល ដែលគេបានប្រើដើម្បីបូជាសពក្មេងម្នាក់។ សព្វថ្ងៃនៅ Bali គ្មាននរណាពន្យល់យើងបានអំពីប្រវត្តិនៃ

---

[២] កំណត់អ្នកប្រែ៖ ខ្មែរហៅថា អាថ័ព្វ ឬអាថាន់។

រូបគោនេះឡើយ។ បើក្រឡេកមើលទៅទំនៀមនៅឥណ្ឌាខាងត្បូងវិញ ផ្នូរបុរាណតែងមានម្លូសធ្វើពីដីដុតផ្ទុកឆ្អឹងសព (ដែលគេមិនដុត)។ ម្លូសទាំងនេះមានជើងមួយៗរាងប៉ោងកណ្ដាលហាក់ដូចជាជើងសត្វ រីឯគម្រប ជួនកាលមានរូបក្បាលសត្វ។ នៅសារមន្ទីរ Madras យើងអាចឃើញម្លូសមួយរបៀបនេះ។ តាមទំនៀម គឺគេបញ្ចុះម្លូសនៅក្នុងផ្នូរ ដែលគេយកផ្ទាំងថ្មមកបញ្ឈរឲ្យកើតជាជញ្ជាំងបួន។ ផ្នូរនោះមិនជ្រៅប៉ុន្មានទេ ពីលើនោះគេយកផ្ទាំងថ្មមួយទៀតមកគ្រប។ គេហ៊ុំពាត់ផ្នូរនោះ ដោយយកដុំថ្មរាយគ្នាជារាងមូល។ ផ្នូរប្រភេទនេះសម្បូណ៌នៅតំបន់ខាងត្បូងនៃក្រុង Madras (ជាពិសេសក្នុងស្រុក Ceṅkalpet) ដែលគេជឿថាជនជាតិ Kurumbar ធ្លាប់រស់នៅរហូតដល់សតវត្សទី៥ ឬទី៦ ហើយត្រូវពួកស្ដេច Pallava និង Cola វាយលុកដេញចេញពីទីនោះ។ ការស្មាននេះប្រហែលជាពិត ពោលគឺផ្នូរទាំងនេះ ប្រហែលជាផ្នូរពួក Kurumbar ត្បិតនៅតំបន់ Maisūr នៅមានជនជាតិ Kuruba និង Kurumba ដែលកិណភាគនិងទំនៀមទម្លាប់ផ្សេងៗត្រូវនឹងការរៀបរាប់នៃឯកសារចេញមកពីប្រភពទមិឡ។ ឯកសារទាំងនោះនិយាយពីជនជាតិ Kurumbar បុរាណដែលរហូតមកសម័យមុននេះមិនយូរប៉ុន្មាន នៅសាងផ្នូរប្រភេទនេះនៅឡើយ (សូមអាន E. Thurston, *Castes and tribes of Southern India*, Madras, 1909, t. IV)។ ប៉ុន្ដែទោះជាមានសក្ខីភាពថា នៅឥណ្ឌាខាងត្បូងនាសម័យបុរាណ គេដាក់សពក្នុងម្លូសលំនាំជាសត្វដូច្នេះក៏ដោយ ក៏ពិបាកនឹងជឿថាមានទំនាក់ទំនងរវាងប្រពៃណីនេះជាមួយទំនៀមនៅ Bali ដែលគេយកសពដាក់នៅក្នុងម្លូសរចនាជារូបសត្វដែរ ព្រោះគ្មានអ្វីទៀតបញ្ជាក់ថា សាសន៍ទាំងពីរនេះធ្លាប់ប្រាស្រ័យទាក់ទងគ្នា។

ផ្ទុយទៅវិញ គប្បីសង្កេតថា ពិធីទីក្សាដែលចែងក្នុងកម្ពីអាគម ធ្វើឲ្យអត្ថនអ្នកដែលបានច្លងទីក្សានោះអាចភ្ជាប់ទៅនឹងព្រះឥសូរ[៣] ហើយយាននៃព្រះឥសូរគឺគោ។ ដូច្នោះ គេអាចស្មានបានថា រូបគោដាក់សពនៅ Bali គឺជាព្រះគោជំនិះព្រះឥសូរដែលអាចនាំសពនោះទៅដល់សិវបទ ពោលគឺស្ថានដ៏ខ្ពង់ខ្ពស់នៃព្រះឥសូរ។ ប្រសិនបើយាននោះជាសត្វដទៃទៀតក្រៅពីគោ ក៏គ្មានបញ្ហាអ្វីដែរ ដូច្នេះហើយបានជាយើងឃើញគេមានប្រើយានជារូបសិង្ហដែរ។ ប៉ុន្ដែសពអ្នកដែលបានច្លងពិធីទីក្សាព្រមទាំងសពតាបស (យតិ) ត្រូវកប់ ពុំត្រូវដុតឡើយ (*Kriyādipikā*, Madras, 1929, p. 263)។ អាស្រ័យហេតុនេះ ទំនៀមបូជាសពនៅក្នុងម្លូសរូបគោ គឺសម្រាប់អនុវត្តន៍លើសៃវា[៤]សាមញ្ញទូទៅ។

ថ្ងៃទី២សីហា១៩៦៧ជាថ្ងៃបូជាសព។ មុននោះគេបានយកសពមកដាក់លើរថបុស្បកជាស្រេច។ រីឯរថ គឺសែងដោយមនុស្ស មិនខុសអ្វីពីគ្រែស្នែងដែលគេនិយមប្រើនៅឥណ្ឌាឡើយ។ ប៉ុន្ដែដោយរថនោះមានទំហំធំខ្លាំង អ្នកសែងមានច្រើនរយនាក់ សែងឆ្លាស់វេនគ្នា។ លុះទៅដល់ទីបូជា គេរំកិលសពចុះតាមក្ដារផ្ដេកដែលពោលមកពីលើ រួចទើបយកសពនីមួយៗមកដាក់ក្នុងម្លូសរូបគោ។ ពេលនោះអាចារ្យធំពីរអ្នក ម្នាក់ខាងសៃវា (padanda Siva) ម្នាក់ទៀតខាងពុទ្ធនិកាយ (padanda Buddha) ធ្វើកិច្ចជម្រះមន្ទិលដោយមានសូត្រមន្ដផ្សេងៗឲ្យសពទាំងពីរ ម្ដងមួយៗ។ បន្ទាប់មក គេយកអុសនិងតង្វាយជាច្រើនមកគរលើនោះបន្ថែមទៀត ទើបគេឲ្យភ្លើង។ រថបុស្បកទាំងមូលក៏ឆេះជាមួយគ្នាទាំងអស់។ ស្អែកឡើងគេរើសធាតុនិងកំទេចផេះដាក់ក្នុងបំណែកម្លូសរូបគោ (ដែលឆេះមិនសព្វអស់) ហើយដង្ហែរយកទៅពន្លិចចោលនៅសមុទ្រ។

នៅថ្ងៃដដែលនោះ មានពិធីបូជាសពច្រើនទៀតដែលគេធ្វើ តែពុំមានភាពអធិកអធំដូចពិធីសពក្សត្រទាំងពីរខាងលើនេះទេ។ គេតែងយល់ថា អ្នកស្រុកដែលពុំសូវមានធនធាន ឆ្លៀតឱកាសធ្វើពិធីរបស់ខ្លួនដើម្បីចំណាយប្រាក់កាសអស់តិច។ ការពិតពុំដូច្នេះឡើយ ត្បិតពិធីនីមួយៗសុទ្ធសឹងតម្រូវឲ្យមានរៀបចំរណ្ដាប់សព្វគ្រប់រៀងៗខ្លួន។ ដូច្នោះមកពីគេទាំងអស់គ្នាជឿថា ជាពេលាល្អសម្រាប់ប្រារព្ធពិធី មិនថានរណាជានរណា។

អំពីការដែលរកឲ្យមានអាចារ្យខាងសៃវាផង ខាងពុទ្ធសាសនាផងនោះ មានការបកស្រាយខុសៗគ្នា។ ម្យ៉ាងគេយល់ថា មកពីអ្នកខ្លះមិនកាន់លទ្ធិសាសនាអ្វីមួយជាប្រាកដ ដូច្នេះដើម្បីឲ្យស្រឡះក្នុងចិត្តចៀសវាងការធ្វើខុស ក៏អញ្ជើញអ្នកទាំងពីរនោះមកសូត្រ។ ឯអ្នកស្រី J. Cuisinier វិញយល់ថា អន្តរាគមន៍អាចារ្យទាំងពីរជាការចាំបាច់ ពីព្រោះ "អ្នកស្រុក Bali មិនខុសអ្វីពីជនជាតិឥណ្ឌូណេស៊ីទូទៅឡើយ គឺតែងជឿថាដំណើរលោកនេះប្រព្រឹត្តទៅនៅលើគោលការណ៍ថា អ្វីៗសុទ្ធសឹងជាគូបដិបក្ខផង ជាគូសម្ព័ន្ធរួមគ្នាផង" (*France-Asie*, XVIII, p.564)។ តាមពិត ការបកស្រាយទាំងនេះពុំស្របនឹងបញ្ញត្តិចែងក្នុងគម្ពីរឡើយ។ បញ្ញត្តិទាំងនោះបង្ហាញឲ្យឃើញថា កិច្ចពិធីខាងសៃវានិងខាងពុទ្ធសាសនាមួយចំនួនគ្មានអ្វីទាស់គ្នាសោះ។ ពាក្យសម្បួងសម្រួងទៅទេពហិណ្ឌូនានា ដែលគង់ប្រចាំទាំងស្ថានមនុស្ស ទាំងស្ថានសួគ៌ បើយកពាក្យឧទ្ទិសទៅព្រះពុទ្ធអង្គនិងព្រះពោធិសត្វនានាដែលសង្គ្រោះលោកមកបន្ថែម ក៏ពុំទាស់ខុសអ្វី។ ជាទូទៅ នៅក្នុងលទ្ធិទាំងពីរនេះ ទស្សនៈអំពីនាមរូបនិងការរំដោះ

---

[៣] កំណត់អ្នកប្រែ៖ ចំណុចនេះ មាន ពោលមកពីខាងលើ។
[៤] កំណត់អ្នកប្រែ៖ សាសនិកដែលគោរពព្រះឥសូរជាធំ។

ចេញពីវដ្តសង្សារ គឺប្រហាក់ប្រហែលគ្នា។ លោក Sylvain Lévi ធ្លាប់បានផ្សព្វផ្សាយអត្ថបទមួយឈ្មោះថា "ពុទ្ធវេទ" ពោលគឺការយល់ដឹងអំពីព្រះពុទ្ធសាសនា ដែលគាត់ជឿថាជាសំណេរស្ដីអំពីកិច្ចពិធីទូទៅ។ តាមពិត គឺជាសំណេរដែលចែងអំពីពិធីសព ហើយដែលបង្ហាញភាពប្រហាក់ប្រហែលគ្នានៃទ្រឹស្ដីសាសនាទាំងពីរ។ ក្នុងនោះ ពាក្យសូត្រខាងសៃវានិងខាងពុទ្ធសាសនា គេរៀបច្លាស់គ្នា។ យើងឃើញថាពុទ្ធសាសនិកសូត្រ និងប្រើទឹកដែលគេឧបកិច្ចថាមកពីទន្លេគង្គាដូចពួកហិណ្ឌូដែរ។ ឯវិន័យដែលសាសនិកត្រូវប្រតិបត្តិតាមការនៅរស់ មានលក្ខណៈខុសគ្នាពីមួយទៅមួយ ប៉ុន្តែលុះបុគ្គលទាំងនោះស្លាប់ទៅ ឥតមានត្រូវប្រតិបត្តិវិន័យអ្វីទៀតឡើយ ដូច្នោះពិធីសពនៃលទ្ធិទាំងពីរនេះប្រហែលគ្នា ដោយសារគេយកទ្រឹស្ដីទាំងពីរមកបញ្ចូលគ្នា។ ចំពោះភាពអធិកអធំនៃពិធីបូជាសពនៅកោះ Bali ដែលគេរៀបចំឡើងក្រោយពីបុគ្គលចែកស្ថានយូរមកហើយនោះ ហាក់ដូចជាពុំស្របនឹងបញ្ញាត្តិនៃគម្ពីរអាគម ដែលចែងតែពីការបូជាភ្លាមៗក្នុងភាពសាមញ្ញ។ ប្រការនេះគួរឲ្យប្រៀបទៅទំនៀមនៅប្រទេសកម្ពុជា ដែលជាប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទមកពីស្រីលង្កា ព្រោះគេតែងធ្វើរបៀបនេះដែរចំពោះសពអភិជន ឬព្រះសង្ឃដែលមានសមណសក្តិខ្ពស់។ នៅកម្ពុជាគេឲ្យហេតុផលទំនៀមនេះ ដោយយកជំនឿអំពីពិធីសពនៃព្រះពុទ្ធអង្គមកពន្យល់ គឺទំនៀមដែលមានចែងក្នុងព្រះត្រៃបិដក។ ទំនៀមនេះក៏មានលាយឡំនិងឥទ្ធិពលឥណ្ឌាទូទៅដែរ។ សំណង់សម្រាប់ធ្វើជាទីបូជាហៅថា "មេន" ពោលគឺ "មេរុ" ដែលមានកំពូលស្រួចទៅលើដូចរថបុស្បកនៅ Bali ដែរ។ ហេតុនេះគេអាចយល់ថា កោះ Bali និងកម្ពុជា គឺសុទ្ធសឹងតែឥទ្ធិពលផ្សេងៗជះមកដូចគ្នា ថ្វីត្បិតតែផ្លូវដែលហូរចូលមកនោះខុសគ្នាពិត។

ជាសារុបមក កិច្ចប្រតិបត្តិសាសនានៅកោះ Bali ពុំមែនជាការចម្លងពីឥណ្ឌាមកទាំងស្រុងដោយងងឹតងងល់ឡើយ។ គឺជាលទ្ធផលនៃសំយោគ ដែលកើតឡើងអំពីឥទ្ធិពលចម្រុះពីប្រភពនានា។ បើគ្រាន់តែប្រៀបធៀបជាមួយទំនៀមនៅប្រទេសជនៃទៃក៏មិនគ្រប់គ្រាន់ដែរ ទាល់តែសិក្សាកម្ពីអត្ថបទដែលមាននៅកោះនេះផ្ទាល់ផង នៅឥណ្ឌាទៀតផង ទើបយើងរកឫសគល់ទាំងអស់ឃើញ។ ដើម្បីឈានមកដល់សំយោគនោះ ឥទ្ធិពលពាក់ព័ន្ធនានាសុទ្ធសឹងឆ្លងកាត់ពេលយ៉ាងយូរ ដោយមានការបូកបញ្ចូលជាមួយទំនៀមបង្កើតថ្មីទៀតផង។ ប្រពៃណីបូជានេះជាភស្តុតាងមួយទៀត ដែលជម្រុញឲ្យយើងទាត់ចោលនូវការអះអាងក្នុង មជ្ឈដ្ឋានអឺរ៉ុបថា នៅអាស៊ីអ្វីៗនៅនឹងថ្កល់ឥតមានការវិវឌ្ឍន៍។